## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង
# រវាង
# សហជីពកម្មករនិយោជិតសណ្ឋាគាររ៉ាហ្វ៊លហ្គ្រែនឌីអង្គរ
# និង
# ក្រុមហ៊ុនសណ្ឋាគាររ៉ាហ្វ៊លហ្គ្រែនឌីអង្គរ

កិច្ចព្រមព្រៀងនេះត្រូវបានធ្វើឡើងនៅថ្ងៃ ទី២៨ ខែតុលា ឆ្នាំ២០២១ រវាងសហជីពកម្មករ និយោជិតសណ្ឋាគាររ៉ាហ្វ៊លហ្គ្រែនឌីអង្គរ (ពីនេះតទៅហៅថា"សហជីព") និង ក្រុមហ៊ុនសណ្ឋាគាររ៉ាហ្វ៊លហ្គ្រែនឌីអង្គរ (ពីនេះតទៅហៅថា "និយោជក")។ ភាគីនីមួយៗអាចហៅដោយឡែកថា "ភាគី" និងហៅជារួមថា "គូភាគី"។

សណ្ឋាគារ Raffles Grand Hotel d'Angkor កំពុងប្រឈមនឹងការលំបាកផ្នែកសេដ្ឋកិច្ចក្នុងកំឡុងពេលនៃជំងឺរាតត្បាតជាសកល COVID-19 ដែលមិនធ្លាប់មានពីមុនមក។ ការផ្ទុះឡើងនៃជំងឺកូរ៉ូណាវីរុសទូទាំងពិភពលោកបានបណ្តាលឱ្យ សណ្ឋាគារត្រូវបង្ខំចិត្តផ្អាកប្រតិបត្តិការរបស់ខ្លួន។ ដូច្នេះ និយោជក និងសហជីព បានធ្វើការចរចា និងព្រមព្រៀងលើការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១២៣នាក់ (ស្រី៣៦នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ២១២នាក់ (ស្រី ៧៨នាក់) រយៈពេល ២២ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២១។

គូភាគីទាំងពីរព្រមព្រៀងគ្នាទទួលយកលក្ខខណ្ឌដូចខាងក្រោម៖

និយោជិតដែលត្រូវបានព្យួរការងារជាបណ្តោះអាសន្ននឹងទទួលបានអត្ថប្រយោជន៍ដូចខាងក្រោម៖

- ១៥% នៃប្រាក់ខែគោលប្រចាំខែ សម្រាប់ប្រធានផ្នែក អនុប្រធានផ្នែក ប្រធានក្រុម និង អនុប្រធានក្រុម ដែលមានប្រាក់ខែច្រើនជាង ១,០០០ ដុល្លារអាមេរិក។
- ២០% នៃប្រាក់ខែគោលប្រចាំខែ សម្រាប់និយោជិតដែលមានប្រាក់ខែតិចជាង ១,០០០ ដុល្លារអាមេរិក ហើយចំនួនប្រាក់ខែអប្បបរិមាដែលទទួលបានគឺ ៦០ ដុល្លារអាមេរិកក្នុងមួយខែក្នុងអំឡុងពេលនៃការព្យួរការងារ។
- និយោជិតនឹងទទួលបាន**អង្ករ ១០ គីឡូក្រាម និង ត្រីខ** ក្នុងមួយខែ។
- រាល់អត្ថប្រយោជន៍ដែលមានស្រាប់ក្នុងអនុសញ្ញារួមនឹងបន្តអនុវត្តដ៏ដែលក្នុងកំឡុងការព្យួរការងារ។
- អតីតភាពការងារនឹងមិនទទួលរងផលប៉ះពាល់។ ក្នុងករណីពិសេសដែលសណ្ឋាគារតម្រូវឲ្យនិយោជិតមកធ្វើការ សណ្ឋាគារនឹងផ្តល់ប្រាក់ឈ្នួល ១០ ដុល្លារអាមេរិកក្នុងមួយថ្ងៃ (៨ ម៉ោង) កំឡុងការព្យួរការងារនេះ។

សណ្ឋាគារនឹងតម្រូវឱ្យនិយោជិតមួយចំនួនបន្តធ្វើការពេញម៉ោងក្នុងអំឡុងពេលនៃការផ្អាកប្រតិបត្តិការនេះដើម្បីថែទាំសណ្ឋាគារ។

- និយោជិតទាំងនេះនឹងទទួលបានប្រាក់ឈ្នួល ១០០% និង ប្រាក់ឧបត្ថម្ភធ្វើដំណើរបន្ថែមចំនួន **៣០ ដុល្លារ** ក្នុងមួយខែ។
- រាល់អត្ថប្រយោជន៍ដែលមានស្រាប់នៅរក្សាដូចធម្មតា។
- និយោជិតដែលបំពេញភារកិច្ចនឹងទទួលបានអាហារធម្មតា។

Raffles Grand Hotel Pte., Ltd.

- និយោជិតទាំងនេះអាចនឹងត្រូវបានស្នើសុំឱ្យបំពេញការងារក្រៅកាតព្វកិច្ចធម្មតារបស់ខ្លួន។ ប៉ុន្តែ ការបណ្តុះបណ្តាលដែលសមរម្យនឹងត្រូវបានផ្តល់ដើម្បីធានាថាកិច្ចការអាចត្រូវបានបញ្ចប់ដោយសុវត្ថិភាព (ឧទាហរណ៍៖ បុគ្គលិកផ្នែកម្ហូបអាហារនិងភេសជ្ជៈធ្វើការសំអាតអាងទឹក)។

សូមបញ្ជាក់ថាកិច្ចព្រមព្រៀងនេះនឹងចាប់ផ្តើមនៅថ្ងៃទី ១ ខែកញ្ញាឆ្នាំ ២០២១ រហូតដល់មានការជូនដំណឹងបន្ថែម។ នៅពេលស្ថានការណ៍កូវីដ -១៩ មានភាពប្រសើរឡើង ហើយយើងមានភាពច្បាស់លាស់អំពីកាលបរិច្ឆេទបើកសណ្ឋាគារឡើងវិញ និយោជកនឹងពិនិត្យឡើងវិញនូវគ្រោងការណ៍ប្រាក់ឈ្នួលទាំងនេះ។

គូភាគីព្រមព្រៀងលើកិច្ចព្រមព្រៀងនេះដោយចុះហត្ថលេខាខាងក្រោមនេះ៖

ចុះហត្ថលេខាតាងនាមភាគីនិយោជក

សៀមរាប ថ្ងៃទី...29... ខែ ...10... ឆ្នាំ២០២១

ហត្ថលេខា និងត្រា

នាយកសណ្ឋាគារ

Raffles Grand Hotel Pte., Ltd.

Dennis de Groot

ចុះហត្ថលេខាតាងនាមភាគីសហជីព

រស ប៊ុនណាល់

ប្រធានសហជីព

មៅ វណ្ណដា

អនុប្រធានសហជីព

ភើង គីរុធ

លេខាធិការសហជីព

ប៉ាត សំបូរ

ប្រធានកិត្តិយសសហជីព